ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 04 / 2008
ម៉ោង (Time/Heure): 16h00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein
des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des Co-juges d'instruction

សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No: 002/14-08-2006

លេខស៊ើបសួរ/Investigation/Instruction
លេខ/No: 001/18-07-2007-ECCC-OCIJ

# កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ
# Report on reconstruction
# Procès verbal de transport sur les lieux

ឆ្នាំ ពីរពាន់ប្រាំបី ថ្ងៃទី ម្ភៃប្រាំមួយ ខែកុម្ភៈ នាវេលាម៉ោង ៨ ព្រឹក

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** *ហៅ* **ឌុច**

ត្រូវបានដាក់អោយស្ថិតក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញា ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤។

បានឃើញវិធាន ៥៥.៨ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញដីការបស់យើងស្តីពីការចុះពិនិត្យដល់ទីកន្លែងចុះថ្ងៃទី ២១ ខែកុម្ភៈឆ្នាំ ២០០៨

យើង **យូ ប៊ុនឡេង** និង **Marcel Lemonde** ជាសហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមានការចូលរួមដោយ លោក ហម ហ៊ើល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជី និង លោក តាន់ ប៊ិាងដាវ័ណ្ណ និង លោក អ៊ូច ចាន់ឈួរ៉ាជាអ្នកបកប្រែដែលបានស្បថរួចហើយ នៃអង្គជំនុំជម្រះវិសាមញ្ញ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

យើងបានចុះដល់ទីកន្លែងមណ្ឌលប្រល័យពូជសាសន៍ ជើង ឯក ដែលស្ថិតនៅចម្ងាយ ១៥ គីឡូម៉ែត្រ ខាងទិសនារតីទី ក្រុងភ្នំពេញ នៅក្នុងខេត្តកណ្ដាល។

នៅទីកន្លែងនោះ យើងឃើញមាន ៖

- លោកស្រី ជា លាង និង លោក Robert PETIT ជាសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ
- លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលចូលរួមដោយមេធាវីរបស់ខ្លួន លោក ការ សាវុត្ថ និង លោក François Roux
- សាក្សី មាស ប៉េងគ្រី ហ៊ឹម ហ៊ុយ ឈុន ផល និង តយ តេង

លោក Zoran LESIC ដែលជាអ្នកជំនាញការចាត់តាំងដោយដីកាចុះថ្ងៃទី ១២ កុម្ភៈ ឆ្នាំ ២០០៨ ក៏មានវត្តមាននៅទីកន្លែងនោះដែរដើម្បីធ្វើរបាយការណ៍របស់លោក និង បានថតរូបដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធជាមួយនឹងរបាយការនេះ(ឧបសម្ព័ន្ធ ១)

*

១- នៅពេលកោះហៅវត្តមាន ជនត្រូវចោទ [រូបថត លេខ ១] ប្រកាសថាស្គាល់តែ ហ៊ឹម ហ៊ុយ ម្នាក់ប៉ុណ្ណោះក្នុងចំណោមសាក្សីទាំង ៤។ លោក ហ៊ឹម ហ៊ុយ [រូបថត លេខ ២] ប្រកាសថាស្គាល់ ឌុច។ សាក្សី មាស ប៉េងគ្រី [រូបថត លេខ ៣] បាននិយាយថាមិនដែលបានជួបជនត្រូវចោទទេ ប៉ុន្តែស្គាល់មុខរបស់ជននេះ។ ចំណែកឯ ឈុន ផលវិញ [រូបថត លេខ ៤] និង តយ តេង [រូបថត លេខ ៥] ប្រកាសថាមិនដែលស្គាល់ជនត្រូវចោទឡើយ។

២- សាក្សី ឈុន ផល និង តយតេង បញ្ជាក់ថា នេះគឺជាលើកទីមួយ ហើយដែលខ្លួនមកកាន់ជើងឯកនេះ។ មាស ប៉េងគ្រី ប្រកាសថាខ្លួនធ្លាប់មកទីនេះម្តង កាលពីឆ្នាំទៅ ដើម្បីថតកុនជាមួយហ៊ឹម ហ៊ុយ។ គាត់បញ្ជាក់ថា គាត់មានឱកាសមកទីកន្លែងនេះជាច្រើនដង ដូចជានៅទសវត្សន៍ទី ៨០ តាមការអញ្ជើញរបស់អ្នកសារព័ត៌មាន និង អង្គការក្រៅរដ្ឋាភិបាល ។

៣- នៅពេលចូលដល់មណ្ឌលនេះ អ្នកចូលរួមត្រូវបានអញ្ជើញអោយរៀបរាប់អំពីអ្វីដែលខ្លួនដឹងទាក់ទងនឹងដំណើរការ <u>ដឹកជញ្ជូន និង ការមកដល់របស់អ្នកទោស។</u>

៣.១ សាក្សី មាស ប៉េងគ្រីពន្យល់ថា នៅពេលដំបូង គាត់បានមកដល់ជើងឯក គឺដើម្បីដឹកជញ្ជូនឈើយកមកសាងសង់ផ្ទះ៖ គាត់បានដឹកឈើយកមកដាក់រួចក៏ត្រឡប់ទៅវិញ។ ក្រោយមក ការដឹកអ្នកទោសក៏ធ្វើដូចគ្នាអញ្ចឹងដែរ។ គាត់បានធ្វើដំណើរតាមផ្លូវដែលដូចសព្វថ្ងៃនេះ (ដែលសម័យនោះ ផ្លូវនេះមិនទាន់ចាក់កៅស៊ូនៅឡើយ ហើយពិបាកទៀត) និង ចូលតាមច្រកចូលបច្ចុប្បន្ននៃជើងឯក [រូបថត លេខ ៦] ហើយចតឡានរបស់គាត់នៅជិតកន្លែងទង់ជ័យបច្ចុប្បន្ន [រូបថត លេខ ៧ និង លេខ ៨]។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

បន្ទាប់ពីអ្នកយាមទទួលអ្នកទោសរួចហើយ គាត់ក៏ត្រឡប់ទៅវិញ។ គាត់ថាបានមកជើងឯក បានតែមួយ ឬ ពីរដងប៉ុណ្ណោះ ៖ តាមពិតទៅ បន្ទាប់ពីឧប្បត្តិហេតុមួយ គាត់ត្រូវបានគេបញ្ជូនទៅ ព្រៃ ស តាមបញ្ជារបស់ ហ៊ឹម ហ៊ុយ ដើម្បីទៅធ្វើស្រែ និង បញ្ឈប់ការដឹកជញ្ជូនទៅជើង ឯក (គាត់ងងុយគេងពេលបើកឡានរបស់គាត់ ហើយក្រឡាប់ទៅក្បែរវត្តស្លែង ប៉ុន្តែមិនមានអ្នកទោសណាម្នាក់នៅលើឡាននោះទេ)។ តាមយោបល់គាត់ មានផ្លាកលេខឡាន ប៉ុន្តែគាត់មិនចាំទេថាលេខប៉ុន្មាន ( **ឈុន ផល** បញ្ជាក់អះអាងថា មានផ្លាកលេខឡាន « ស-21 » សម្រាប់ឡានកាមីញ៉ុង)។

៣.២ សាក្សី **ហ៊ឹម ហ៊ុយ** ប្រកាសថាជាទូទៅ ខ្លួនបានរៀបចំដឹកជញ្ជូនអ្នកទោសចន្លោះម៉ោង ៨ និង ៩ ល្ងាច។ ពួកគេមកដោយត្រូវបានចងស្លាបសេក បិទមុខរហូតដល់ចប់ និង ត្រូវបានយកទៅដាក់នៅក្នុងផ្ទះមុនពេលយកទៅសម្លាប់។ គាត់គូសបញ្ជាក់ថាចំនួននៃការដឹកជញ្ជូនគឺប្រែប្រួលរវាង មួយលើកក្នុងមួយសប្តាហ៍ និង មួយលើក ឬ ពីរលើកក្នុងមួយខែ។ គាត់បន្ថែមថាគាត់មិនមែនជាអ្នកទទួលបន្ទុកការដឹកជញ្ជូននេះតែម្នាក់ឯងទេ។

៣.៣ សាក្សី **ឥយ តេង** បញ្ជាក់ថា ខ្លួនត្រូវបានគេចាត់តាំងអោយយាមអ្នកទោស ហើយខ្លួនមានវត្តមាននៅពេលទទួលអ្នក-ទោស។

៣.៤ សាក្សី **ឈុន ផល** មិនមានអ្វីនិយាយអំពីការដឹកអ្នកទោសទេ ដោយសារខ្លួនជាអ្នកយាមនៅ ស-២១ មិនមែននៅទីនេះទេ។

៣.៥ ជនត្រូវចោទប្រកាសថា ការចង្អុលបង្ហាញដោយសាក្សីមិនមានអ្វីដែលត្រូវកែតម្រូវអំពីគាត់នោះទេ។

៤- បន្ទាប់មក អ្នកចូលរួមត្រូវបានអញ្ជើញអោយចូលទៅ<u>ទីតាំងផ្ទះឈើ</u> ដែលគេឃុំអ្នកទោសមុនពេលសម្លាប់ [រូបថតលេខ៩] ។

៤.១ សាក្សី **មាស ប៉េងគ្រី** ចង្អុលបង្ហាញអំពីទីតាំងផ្ទះនេះ [រូបថត លេខ ១០] ហើយបញ្ជាក់ថាវាមានទំហំ ទទឹង ៤ ម និង បណ្តោយប្រមាណ ៨ ម ក្នុងកម្ពស់ពីរជាន់ (ជាន់ផ្ទាល់ដី និង ជាន់ទីមួយ) ។

៤.២ សាក្សី **ឥយ តេង** មានការច្របូកច្របល់បន្តិច ដោយសារបរិយាកាសមានការផ្លាស់ប្តូរ ប៉ុន្តែគាត់បញ្ជាក់អំពីទីតាំងរបស់ផ្ទះឈើនេះ។ គាត់គូសបញ្ជាក់ថា ម៉ាស៊ីនភ្លើងនៅជិតខ្ទមតូចដែលមានសព្វថ្ងៃនេះ [រូបថត លេខ ១១] ។ តាមសំដីរបស់គាត់ អ្នកទោសមិនចំណាយពេលនៅក្នុងផ្ទះនេះយូរទេមុនយកទៅសម្លាប់។ គាត់ពន្យល់ថាគាត់បានកាន់បញ្ជីមួយ គូសអ្នកដែលមកដល់ និង អ្នកដែលត្រូវយកទៅសម្លាប់ ដើម្បីកុំអោយបាត់ម្នាក់។ គាត់ប៉ាន់ស្មានចំនួនអ្នកទោសដែលមានវត្តមានក្នុងពេលដំណាលគ្នាប្រមាណជា ២០ ឬ ៣០ រូប តែមិនច្បាស់ទេ។

៤.៣ សម្រាប់ខ្លួនគាត់ សាក្សី **ហ៊ឹម ហ៊ុយ** ប្រកាសថាអ្នកទោសមួយលើកៗមានចំនួនប្រមាណ ៥០ និង ៦០ នាក់ និង ថាគាត់នៅទីងកន្លែងនោះយូរបំផុត ១ ម៉ោ។ គាត់បញ្ជាក់ថា នៅពេលដែលអ្នកទោសមកដល់ គេធ្វើបញ្ជីមួយដើម្បីធ្វើការប្រៀបធៀបជាមួយបញ្ជីនៅ ស-២១។ ការធ្វើបញ្ជីនេះចំណាយពេលពីកន្លះម៉ោង ទៅ មួយម៉ោង។ ពេលត្រឡប់ទៅ ស ២១ វិញ ហ៊ឹម ហ៊ុយរាយការណ៍ទៅ **ស្ទួស ធី**។

៥. បន្ទាប់មក អ្នកចូលរួមត្រូវបានអញ្ជើញទៅ **<u>កន្លែងសម្លាប់</u>** [រូបថត លេខ ១២] ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

៥.១ សាក្សី **ហ៊ឹម ហ៊ុយ** ទទួលស្គាល់ទីតាំងដើមត្នោត [រូបថត លេខ ១៣] និង **ផ្នូរចិន** [រូបថត លេខ ១៤] ដែលគាត់បាននិយាយនៅក្នុងភាពយន្តរបស់ រិទ្ធី ប៉ាន« ស-21 » ។

៥.២ សាក្សី **ឈុន ផល** បញ្ជាក់ថាបានមកទីនេះតែម្តងគត់ គឺនៅចុងឆ្នាំ ១៩៧៨ ដើម្បីកប់សាកសព។ គាត់អាចបញ្ជាក់បានថាអ្នកទាំងអស់នោះបានស្លាប់រួចហើយ ប៉ុន្តែមិនអាចបញ្ជាក់អំពីចំនួនសាកសពឡើយ ដោយហេតុថានៅពេលយប់ ហើយគាត់មិនបានរាប់។ គាត់បញ្ជាក់បន្ថែមថា គាត់ « ជីកនៅពេលថ្ងៃ ហើយកប់នៅពេលយប់ » ។ គាត់ថាមិនបានចាំច្បាស់ទេថារណ្តៅដែលគាត់ជីកនៅទីណាទេ និង មិនបានចាំច្បាស់ទេអំពីផ្នូរចិនឡើយ។

៥.៣ សាក្សី **តយ តេង** ប្រកាសថាមិនអាចកំណត់ទីតាំងច្បាស់លាស់ឡើយព្រោះដើមឈើបានលូតលាស់ធំណាស់។

៥.៤ នៅជិតរណ្តៅដែលគេរកឃើញឆ្អឹងរបស់ក្មេង [រូបថត លេខ ១៥ និង ១៦] សាក្សីប្រកាសថាទាំងអស់គ្នាមិនដែលឃើញមានក្មេងនៅជើងឯកទេ៖ **តយ តេង** ដែលបញ្ជាក់ថាធ្លាប់ធ្វើការនៅជើងឯក៥ ទៅ ៦ ខែ គឺនៅឆ្នាំ ១៩៧៨ រហូតដល់រំដោះ រំលឹកថាខ្លួនបានឃើញមានបុរស និង ស្ត្រី ប៉ុន្តែមិនដែលឃើញមានកុមារឡើយ។ គាត់បញ្ជាក់ថាស្ត្រី និង បុរសត្រូវបានសម្លាប់ ហើយកប់នៅកន្លែងជាមួយគ្នា។ **មាស ប៉េងគ្រី** បញ្ជាក់ផងដែរថាគាត់មិនដែលឃើញមានក្មេងទេ។ **ឈុន ផល** ប្រកាសថាមិនដែលមានសសាកសពរបស់ក្មេងក្នុងចំនោមសាកសពដែលគាត់បានកប់។ **ហ៊ឹម ហ៊ុយ** បញ្ជាក់ថាគាត់មិនដែលឃើញមានក្មេងក្នុងចំណោមអ្នកទោសដែលដឹកជញ្ជូនទេ ប៉ុន្តែរំលឹកថាខ្លួនមិនមែនជាអ្នកទទួលបន្ទុកដឹកជញ្ជូនតែម្នាក់ឯងទេ។ គាត់បន្ថែមថាក្មេងដែលត្រូវបានចាប់ខ្លួនត្រូវបានសម្លាប់នៅ ស ២១ ហើយ **ប៉េង** ជាអ្នកទទួលបន្ទុករឿងនេះ។ ជនត្រូវចោទប្រកាសថាក្មេងដែលត្រូវចាប់ខ្លួនត្រូវបានសម្លាប់នៅជើងឯក ឬ នៅ ស-២១។ ជនត្រូវចោទបញ្ជាក់ថា ខ្លួនមិនបានដឹងអំពីការប្រើប្រាស់គល់ឈើដើម្បីសម្លាប់ក្មេងនោះទេ[**រូបថត លេខ ១៧**] ដោយបន្ថែមថាខ្លួនមិនមែនជាអ្នកបញ្ជាទេ ប៉ុន្តែរឿងនេះអាចមានកើតឡើងមែន។

៦. ក្រោយមក អ្នកចូលរួមប្រមូលផ្តុំគ្នានៅជុំវិញរណ្តៅ ដែលតាមសំដីរបស់ហ៊ឹម ហ៊ុយ ឌុចមានវត្តមាននៅពេលសម្លាប់ [រូបថត លេខ ១៨] ។

៦.១ សាក្សី **ហ៊ឹម ហ៊ុយ** ផ្លាស់ប្តូរចម្លើយរបស់ខ្លួនទាក់ទងទៅនឹងចំនួននៃការមកពិនិត្យរបស់ **ឌុច** ៖ បន្ទាប់ពីបានគូសបញ្ជាក់ថាជននេះ « *យូរៗមកម្តង* » គាត់ប្រកាសថាគាត់មិនចាំច្បាស់ទេថា **ឌុច** បានមកប៉ុន្មានលើក « ប៉ុន្តែ យ៉ាងហោចណាស់ក៏ពីរលើកដែរ» ។ បន្ទាប់មក សាក្សីបាននិយាយលំអិតអំពី ការមកពិនិត្យ « មួយលើកនោះ » របស់ **ឌុច** និង **ហ៊ី** ដោយពន្យល់ថា ពេលនោះ ខ្លួននៅក្នុងផ្ទះកំពុងរវល់អំពីបញ្ជីនាទា នីរសាររបស់ **ឌុច** បានមករកគាត់។ គាត់ក៏បានទៅកន្លែងរណ្តៅ ដែល **ឌុច** មានវត្តមាន ហើយកំពុងជក់បារី។ គាត់ចាំយ៉ាងច្បាស់ត្រង់កន្លែងដែល **ឌុច** សួរគាត់ថា « តើគាត់ដាច់ខាត ឬ មិនដាច់ខាត » ហើយធ្លាប់រៀបរាប់អំពីរបៀបដែលយកដែករទេះសម្លាប់មនុស្ស។ មានចំនុចស្រពិចស្រពិលមួយចំនួននៅក្នុងចម្លើយរបស់គាត់ស្តីអំពីចំនួនអ្នកទោសដែលគាត់បានសម្លាប់ ដោយគាត់បញ្ជាក់ថា **ឌុច** បញ្ជាអោយគាត់សម្លាប់អ្នកទោសតែម្នាក់ទេ ចំពោះអ្នកផ្សេងទៀតត្រូវបានសម្លាប់ដោយក្រុមរបស់ **តយ តេង** ហើយថាមិនមែននៅថ្ងៃជាមួយគ្នាទេដែលហ៊ីបានបញ្ជាអោយខ្លួនសម្លាប់អ្នក



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ទោស ៤ រូប។

៦.២ ជនត្រូវចោទបដិសេធដាច់អហង្ការនូវការអះអាងបែបនេះ ៖ **ឌុច** បញ្ជាក់ថាខ្លួនមិនដែលមកដល់កន្លែងដែល **ហ៊ឹម ហ៊ុយ** និយាយទេ ហើយនិយាយដដែលថា មានពេលតែម្តងគត់ដែលខ្លួនមក ជើងឯក គឺមកត្រឹមក្បែរផ្ទះនេះ និង មកប្រហែលជាប៉ុន្មាននាទីតែប៉ុណ្ណោះ ដោយយកលេសថាតេអូរបស់ខ្លួនមិនដើរ ដើម្បីត្រឡប់ទៅភ្នំពេញវិញ។ គាត់អះអាងថា **ហ៊ឹម ហ៊ុយ** អាចមានបញ្ហា គាត់អាចភ័យថាគេចោទគាត់ជាប្រធាន ស-២១ ព្រោះគាត់ធ្លាប់ជាប់គុកអស់ ១០ ខែ ។ ដូច្នេះ គាត់ភរអំពីបញ្ហានេះ ហើយ «បន្តភរដើម្បីរក្សាកិត្តិយសរបស់គាត់»។ **ហ៊ឹម ហ៊ុយ**រក្សាចម្លើយរបស់ខ្លួនដដែល។

៦.៣ សាក្សី **តយ តេង** លើកឡើងថាខ្លួនមិនដែលដឹងអំពីហេតុការណ៍ដែលរៀបរាប់ដោយ **ហ៊ឹម ហ៊ុយ** ទេព្រោះថា « ខ្លួននៅតែក្នុងផ្ទះ»។ គាត់បញ្ជាក់ថាមិនដែលឃើញ **ឌុច** ទេ ឃើញតែសមមិត្ត ហ៊ី ៖ អាចថា **ឌុច** មកជើងឯក ដោយគាត់មិនបានឃើញ ប៉ុន្តែគាត់មិនដែលលឺគេនិយាយអំពីរឿងនេះទេ។

៧. អ្នកចូលរួមត្រូវបានអញ្ជើញអោយបញ្ជាក់អំពី **<u>តួនាទីរៀងៗខ្លួន</u>** នៅជើងឯក។

៧.១ សាក្សី **ហ៊ឹម ហ៊ុយ** រៀបរាប់ផងដែរអំពីអ្វីដែលមានជាឋានានុក្រមនាសម័យនោះ ៖ **ឌុច**គឺជាថ្នាក់លើរបស់ហ៊ី ដែលជាថ្នាក់លើរបស់ **ផល** ដែល**ផល**នេះជាថ្នាក់លើរបស់**ប៉េង** ដែលមានប៊្លីនៅក្រោមបញ្ជារបស់ខ្លួន។ **ហ៊ឹម ហ៊ុយ**ពន្យល់ថាហ៊ីបានបញ្ជាអោយខ្លួនចាត់តាំងអង្គភាពមួយទទួលបន្ទុកនៅជើងឯក។ គាត់បញ្ជាក់ថាគាត់មិនដែលទទួលបញ្ជាពីឌុចទេ តែពី ហ៊ីប៉ុណ្ណោះ ហើយថាគាត់បានបញ្ជាបន្តទៅ**តយ តេង**។ អង្គភាពរបស់ **តយ តេង** ដែលមានគ្នា ៨ នាក់ ស្ថិតនៅជើងឯកពីឆ្នាំ ១៩៧៧ រហូតដល់ពេលរំដោះ។ គាត់ទទួលបន្ទុកទទួលអ្នកទោស ជីករណ្តៅ យាម និងសម្លាប់អ្នកទោស។

៧.២ សាក្សី **តយ តេង** បញ្ជាក់អះអាងថាខ្លួនត្រូវបានចាត់តាំងទៅជើងឯកដោយ**ហ៊ឹម ហ៊ុយ** ដែលជាអ្នកដែលខ្លួនទទួលបញ្ជាពី និងថាភារកិច្ចរបស់ខ្លួនគឺទទួលអ្នកទោសនៅពេលមកដល់ ជីករណ្តៅ និង កប់វិញបន្ទាប់ពីការសម្លាប់។ បន្ទាប់ពីបានប្រកាសថា នៅពេលដែលអ្នកទោសត្រូវបានបញ្ជូនទៅរណ្តៅ « គាត់ប្រចាំការនៅក្នុងផ្ទះ ហើយមិនដឹងមានរឿងអ្វីកើតមានឡើងនោះទេ » ។ គាត់សារភាពថាសមាជិករបស់អង្គភាពគាត់គឺទទួលបន្ទុកការសម្លាប់ និង ទទួលស្គាល់ដោយខ្លួនឯងថាបានសម្លាប់ផ្ទាល់ដោយខ្លួនឯងផងដែរនៅពេលខ្លះ ប៉ុន្តែបញ្ជាក់ថា « វាមិនមែនជាភារកិច្ចប្រចាំថ្ងៃឡើយ ».

៧.៣ ជនត្រូវចោទពន្យល់ថាកងអនុសេនាធំមួយ-ដែលមានគ្នាប្រហែលជាង ១០០ នាក់- ទទួលបន្ទុកយាមកាម និង សម្លាប់អ្នកទោសនៅជើងឯក។ មុនពេលការមកដល់របស់**ហ៊ឹម ហ៊ុយ** មានកងពិសេសមួយដែលដឹកនាំដោយ **ប៉េង** ដែលតួនាទីនេះសំខាន់ជាង **ហ៊ុយ** ទៅទៀត។ ហ៊ុយ គឺស្ថិតនៅក្រោមបញ្ជារបស់ **ប៉េង**។ ជនត្រូវចោទគូសបញ្ជាក់ថា **ហ៊ុយ**ស្ថិតនៅក្រោមខ្លួនដល់ទៅ ៣ ថ្នាក់ឯណោះ ៖ **ហ៊ុយ** នៅក្រោមបង្គាប់របស់ **ផល** ដែលស្ថិតនៅក្រោម**ប៉េង** ហើយ**ប៉េង**ស្ថិតនៅក្រោមហ៊ី។ តាមយោបល់របស់គាត់ គម្លាតឋានានុក្រមនេះមិនទំនងជាអាចមានហេតុការណ៍នៅកន្លែងរណ្តៅដូចការពន្យល់របស់ **ហ៊ុយ** ឡើយ ៖ **ឌុច**គ្មានហេតុផលដែលត្រូវសាកល្បង**ហ៊ុយ**ពីភាពស្មោះត្រង់របស់គេដោយសួរពីរឿងដាច់ខាត ឬ មិនដាច់ខាត និង ដោយបង្ខំអោយសម្លាប់មនុស្សនោះទេ។ ប្រសិនបើ **ហ៊ឹម ហ៊ុយ**មិនធ្វើការងាររបស់ខ្លួន **ប៉េង** នឹងរាយការណ៍អោយហ៊ី ដែលនឹងរាយការណ៍អោយខ្លួន ហើយខ្លួននឹងប្រាប់**សុន សេន** ។ **ឌុច**គួរតែធ្វើការរិះគន់ទៅហ៊ី មិនមែនហ៊ុយទេ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ជាចុងបញ្ចប់ ឌុចនៅតែអះអាងថាខ្លួនទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់ ស ២១ រួមទាំងការកាប់សម្លាប់ផង។ ជនត្រូវចោទមិនបានចាំទេថាតើការសម្រេចបញ្ជូនការសម្លាប់នៅជើង ឯកត្រូវបានធ្វើតាមគំនិតរបស់ខ្លួន ឬ តាមគំនិតរបស់ហ៊ី ប៉ុន្តែទទួលស្គាល់ថាការសម្រេចបែបនេះមិនអាចធ្វើដោយគ្មានការយល់ព្រមរបស់ខ្លួនឡើយ។

*

បន្ទាប់ពីប្រតិបត្តិការសំដែងឡើងវិញខាងលើ អ្នកចូលរួមទាំងអស់ចាកចេញពីទីកន្លែងនាវេលាម៉ោង ១២ និង ១៥ នាទី ដោយគ្មានឧប្បត្តិហេតុអ្វីឡើយ។

ការសំដែងឡើងវិញត្រូវបានថតជាសម្លេង និង ជារូបភាព ដែលបានប្រគល់អោយជនត្រូវចោទមួយច្បាប់ផងដែរ។

ឯកសារដើមនៃកំណត់ហេតុនេះត្រូវបានតាក់តែងឡើងជាភាសាខ្មែរ និង បារាំង និងបកប្រែជាភាសាអង់គ្លេស។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០៨

ក្រឡាបញ្ជី

Les Greffiers

LY Chantola    លី ចាន់តូឡា

សហចៅក្រមស៊ើបអង្កេត

Co- investigating Judges

Co-juges d'instruction

MARCEL Lemonde    យូ ប៊ុនឡេង